វិទ្យាស្ថានបើកទូលាយ
Open Institute

# របាយការណ៍សង្ខេបលទ្ធផល នៃកិច្ចប្រជុំវេទិកាស្ត្រី
# ស្តីពី
# «តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាក្នុងបញ្ចប់អំពើហិង្សាលើស្ត្រី»

## សម្រាប់សិក្ខាសាលា ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០៨





រៀបចំដោយ៖

អំពីស្ត្រី

ឧបត្ថម្ភដោយ៖

OPEN SOCIETY INSTITUTE
& Soros Foundations Network

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN
aecid

## តារាងមាតិកា

I.អំពើហិង្សាលើស្ត្រី.......................................................................១
II. គោលបំណងនៃកិច្ចប្រជុំ.......................................................................២
III.សកម្មភាព នៃកិច្ចប្រជុំវេទិកាស្ត្រី.......................................................................២
IV.ការរកឃើញ.......................................................................៣
V.អនុសាសន៍.......................................................................៥
VI.សេចក្តីសន្និដ្ឋាន.......................................................................៦

អំពីស្ត្រី

# របាយការណ៍ សង្ខេប លទ្ធផល នៃកិច្ចប្រជុំវេទិកាស្ត្រី
# ស្តីពី
# «តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី»

គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា[១]៖

គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ៣៖ ជំរុញសមភាពយេនឌ័រ និងការផ្តល់អំណាចដល់ស្ត្រី

| | |
|---|---|
| គោលដៅរូម ៨ ៖ | ធ្វើឲ្យមានការកាត់បន្ថយគួរឲ្យកត់សម្គាល់នូវរាល់ទម្រង់នៃអំពើហិង្សាលើស្ត្រី និង កុមារ |
| គោលដៅ ៣.១៧៖ | បង្កើនភាគរយនៃការយល់ដឹងរបស់ប្រជាជនថា អំពើហិង្សាលើស្ត្រី និងកុមារ គឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ ឲ្យបាន១០០% នៅឆ្នាំ២០១៥។ |

## I. អំពើហិង្សាលើស្ត្រី

### *ក. និយមន័យ ៖*

អំពើហិង្សាលើស្ត្រីមានច្រើនប្រភេទ រួមមានអំពើហិង្សាលើរូបរាងកាយ លើផ្លូវចិត្ត ផ្លូវសេដ្ឋកិច្ច ។ល។ កាលពីឆ្នាំ ១៩៩៣ មហាសន្និបាតអង្គការសហប្រជាជាតិ បានដាក់ចេញនូវនិយមន័យនៃពាក្យអំពើហិង្សាលើស្ត្រី។ នៅក្នុងសេចក្តីថ្លែងការណ៍ស្តីពីការលុបបំបាត់អំពើហិង្សាលើស្ត្រី ដែលត្រូវបានមហាសន្និបាតអនុមតិ (General Assembly resolution 48/104 of 20 December 1993 [២]) ហើយត្រូវបានគេប្រើប្រាស់ទូលំទូលាយនោះ មាត្រាមួយបានចែងថា" អំពើហិង្សាលើស្ត្រី" មានន័យថា អំពើហិង្សាទាក់ទងយេនឌ័រទាំងឡាយណា ដែលនឹងនាំឲ្យមានគ្រោះអន្តរាយ ឬការឈឺចាប់ផ្លូវរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ដោយរួមមានការគំរាមកំហែង បង្ខិតបង្ខំ ឬរំលោភបំពាន សេរីភាព ដែលអំពើទាំងនោះកើតឡើងនៅទីសាធារណៈ ឬជីវិតឯកជន។

### *ខ. ស្ថានភាពទូទៅ ៖*

តាមតួលេខទទួលបាន អំពើហិង្សាលើស្ត្រីមានការរីករាលដាលគួរឲ្យភ្ញាក់ផ្អើល។ គេប៉ាន់ប្រមាណជាទូទៅថា ក្នុងចំណោមស្ត្រី ៣នាក់នៅទូទាំងពិភពលោក មានម្នាក់នឹងត្រូវទទួលរងនូវការឈឺចាប់ដោយ អំពើហិង្សាទាក់ទងយេនឌ័រ នៅក្នុងជីវិតរស់នៅរបស់ពួកគេ។ អំពើទាំងនោះ រួមមានការវាយដំ រំលោភ ការវាយប្រហារ ការត្រូវគេជួញដូរ ត្រូវគេសម្លាប់ ការប្រមាថ ការដាក់កំហិតក្នុងការដើរហើរ និងទំនាក់ទំនង

១. http://www.mop.gov.kh/Default.aspx?tabid=156

២. http://www.unhchr.ch/huridocda/huridoca.nsf/(Symbol)/A.RES.48.104.En

សង្គម។ល។ (UN Commission on the status of women 28/2/00)[៣]

អំពើហិង្សាលើស្ត្រីបានធ្វើឲ្យអន្តរាយដល់សមភាពយេនឌ័រ។ អំពើហិង្សាលើស្ត្រី គឺជាលទ្ធផលដែលអាចមើលឃើញច្បាស់អំពីអសមភាពយេនឌ័រ និងការខ្វះអំណាចរបស់ស្ត្រី។ ដូច្នេះហើយ យើងមិនអាចសម្រេចបានគោលដៅអភិវឌ្ឍសហស្សវត្សឡើយ ប្រសិនបើអំពើរំលោភបំពាននេះនៅតែកើតមាន (Ending Violence against Women and Girls-Protecting Human Rights, GTZ)។

## II. គោលបំណងនៃកិច្ចប្រជុំ

កិច្ចប្រជុំវេទិកាស្ត្រីធ្វើឡើងក្នុងគោលបំណង៖

> ជំរុញសមភាពយេនឌ័រក្នុងសង្គមមួយ ដែលស្ត្រីអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនមានគុណភាព និងអាចកសាងសមត្ថភាព ដើម្បីក្លាយជាអ្នកមានភាពម្ចាស់ការ

១. ស្វែងយល់ និងវិភាគអំពីប្រភពនៃបញ្ហាការរើសអើង និងទំនាក់ទំនងរវាងហេតុ និងផល
២. ធ្វើការវិភាគ ស្វែងរកយុទ្ធសាស្ត្រ និងការតស៊ូមតិសមស្រប សម្រាប់ដំណោះស្រាយជារួម
៣. បញ្ជ្រាបការយល់ដឹងអំពីសិទ្ធិ ដើម្បីឈានទៅរកការលុបបំបាត់នូវការរើសអើង បង្កើនសមត្ថភាពចាំបាច់ និងសមត្ថភាពក្នុងភាពជាអ្នកដឹកនាំសម្រាប់ស្ត្រី

## III. សកម្មភាព នៃកិច្ចប្រជុំវេទិកាស្ត្រី

ដើម្បីចូលរួមក្នុងយុទ្ធនាការពិភពលោក «**ការនិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី**» កម្មវិធីស្ត្រីនៃអង្គការ **វិទ្យាស្ថានបើកទូលាយ** បានរៀបចំកិច្ចប្រជុំវេទិកាស្ត្រីចំនួន៣លើក លើប្រធានបទស្តីពី «**តម្រូវការប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី**» កាលពីខែកញ្ញា រហូតដល់ខែវិច្ឆិកាកន្លងមក នាអង្គការវិទ្យាស្ថានបើកទូលាយ។ កិច្ចប្រជុំវេទិកាស្ត្រីទាំងបី មានការអញ្ជើញចូលរួម ជាង ៧០នាក់ដែលជាតំណាង មកពីស្ថាប័នចំនួន៣០ ដែលជាស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នដែលធ្វើការងារអំពីស្ត្រី សិទ្ធិ សិក្សាស្រាវជ្រាវ និងស្ថាប័នសារព័ត៌មាន រួមមាន៖ ក្រសួងកិច្ចការនារី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គម្រោងមូលនិធិសហប្រជាជាតិសម្រាប់ការអភិវឌ្ឍន៍ស្ត្រី(UNIFEM) ប្រចាំនៅកម្ពុជា គម្រោងគាំទ្រនីតិបញ្ញត្តិកម្ពុជា-កាណាដា គណៈកម្មាធិការលុបបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ សមាគមអភិវឌ្ឍន៍សុខភាពប្រជាជន អង្គការប្រឆាំងអំពើហិង្សាក្នុងគ្រួសារ មណ្ឌលព័ត៌មានស្ត្រីកម្ពុជា កម្មវិធីនៃរាជាណាចក្រកម្ពុជា សមាគមអភិវឌ្ឍន៍ស្ត្រីកម្ពុជា អង្គការបំលាស់ប្តូរជាវិជ្ជមានសម្រាប់កម្ពុជា អង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា អង្គការសិទ្ធិមនុស្សលីកាដូ អង្គការចំរើនស្ត្រី អង្គការកម្ពុជាជួយស្ត្រីមានវិបត្តិ មជ្ឈមណ្ឌលសម្លេងស្ត្រីខ្មែរ អង្គការផេក-កម្ពុជា អង្គការអ៊ិកផាត-កម្ពុជា អង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា សមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ សមាគមនារីអភិវឌ្ឍន៍ អង្គការជំនួយរបស់វិហារដាណឺម៉ាក អង្គការActionaid International ការិយាល័យ

៣. http://www.peacewomen.org/un/ecosoc/CSW/CSWindex.html

សម្រាប់ការសហការរបស់កាណាដា ក្រុមហ៊ុនទូរស័ព្ទភូមិកម្ពុជា សមាគមយុវជនខ្មែរ សារព័ត៌មានកំបូដស័រ វិទ្យុសំលេងប្រជាធិបតេយ្យ និងសកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

កិច្ចប្រជុំវេទិកាស្ត្រីមានការផ្តល់ជាបទឧទ្ទេសនាមពីសំណាក់វាគ្មិនដែលមានជំនាញ និង បទពិសោធន៍ផ្នែកយេនឌ័រ ច្បាប់ សិទ្ធិនៅក្នុងប្រទេសកម្ពុជា អំពីបទពិសោធន៍ការងារ និងសកម្មភាពរបស់ស្ថាប័នដែលធ្វើការទាក់ទងនឹងអំពើហិង្សាលើស្ត្រី ឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ឆ្នាំ២០១៥។ កិច្ចប្រជុំបានពិភាក្សា និងផ្លាស់ប្តូរយោបល់ និងបទពិសោធន៍គ្នាទៅវិញទៅមកយ៉ាងផុលផុសពីសំណាក់អ្នកចូលរួម។ ជាលទ្ធផល កិច្ចប្រជុំវេទិកាស្ត្រីបានរកឃើញនូវចំណុចមួយចំនួន និងបានផ្តល់ជាអនុសាសន៍មួយចំនួនផងដែរ។

បន្ថែមទៅលើនេះ កម្មវិធីស្ត្រី ក្រោមកិច្ចសហការជាមួយអង្គការយូនីហ្វេមប្រចាំទីក្រុងញ៉ូវយក អង្គការយូនីហ្វេមប្រចាំតំបន់អាស៊ីខាងកើត និងអាស៊ីអាគ្នេយ៍ អង្គការយូនីហ្វេមប្រចាំប្រទេសកម្ពុជា បានធ្វើមូលដ្ឋានីយកម្មទៅលើទម្រង់«**ការនិយាយថា ទេ ចំពោះអំពើហិង្សាលើស្ត្រី**» ដាក់លើវិបផតថលស្តីអំពីស្ត្រី និងបានអញ្ជើញអ្នកអានវិបផតថលផ្តល់ហត្ថលេខាគាំទ្រលើយុទ្ធនាការនេះ។ នៅក្នុងយុទ្ធនាការនេះ យើងប្រមូលបានហត្ថលេខាគាំទ្រសរុបចំនួន **៥០៧៥** ដែលក្នុងនោះ ហត្ថលេខាគាំទ្រចំនួន **៣៨៥១** បានមកពីសមាគមអភិវឌ្ឍន៍សុខភាពប្រជាជនក្រោមកិច្ចសហការប្រមូលហត្ថលេខា **២២៧**ហត្ថលេខាបានមកពីអង្គការយូនីហ្វេម ប្រចាំនៅកម្ពុជា និងហត្ថលេខាចំនួន **៩៩៧** បានមកកម្មវិធីស្ត្រីនៃអង្គការវិទ្យាស្ថានបើកទូលាយ។ ហត្ថលេខាទាំង **៥០៧៥** នេះ ត្រូវបានបញ្ជូនទៅអង្គការយូនីហ្វេមប្រចាំទីក្រុងញ៉ូវយក កាលពីថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០០៨ ដើម្បីផ្ញើជូនឯកឧត្តម បាន គីមូន អគ្គលេខាធិការ អង្គការសហប្រជាជាតិ សម្រាប់គាំទ្រកិច្ចខំប្រឹងប្រែងរបស់ឯកឧត្តម ក្នុងទិវាប្រឆាំងអំពើហិង្សាលើស្ត្រី នាថ្ងៃទី ២៥ ខែវិច្ឆិកា ឆ្នាំ២០០៨។

## IV. ការរកឃើញ

កិច្ចប្រជុំវេទិកាស្ត្រីបានរកឃើញនូវចំណុចមួយចំនួន ដូចខាងក្រោម៖

- **ហេតុផលទាក់ទងអំពើហិង្សាលើស្ត្រី៖**
  ១. វប្បធម៌របស់សង្គមកម្ពុជាតែងតែអោយតម្លៃទៅលើបុរសខ្ពស់ជាងស្ត្រី បញ្ហាសង្គម បញ្ហាអប់រំ ភាពក្រីក្រ និងទំនៀមទម្លាប់ប្រពៃណីមួយចំនួនបានគាបសង្កត់រាំងស្ត្រីមិនអោយស្ត្រីទទួលសិទ្ធិបានពេញលេញ
  ២. អំពើហិង្សាភាគច្រើន គឺកើតឡើងពីបុរស និងពីភាពជាបុរស
  ៣. អំពើហិង្សាមានការកើនឡើងក្នុងរូបភាពកាន់តែឃោរឃៅជាងមុន តាមច្រើនរូបភាព និង កើតឡើងស្ទើរតែលើមនុស្សគ្រប់ៗគ្នា ដែលកម្រនឹងត្រូវបានលាតត្រដាងណាស់

- **ផលប៉ះពាល់ នៃអំពើហិង្សាលើស្ត្រី៖**
  ១. ស្ត្រីដែលជាជនរងគ្រោះភាគច្រើនគឺមិនហ៊ាននិយាយចេញនោះទេ ពីព្រោះពួកគាត់ខ្លាចសង្គមមើលងាយ ធ្វើឲ្យប៉ះពាល់ដល់សតិបញ្ញា សុខភាព ជីវភាពគ្រួសារ បាត់បង់អនាគត ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចដែលនេះមិនត្រឹមតែប៉ះពាល់ដល់ជនរងគ្រោះប៉ុណ្ណោះទេ តែគឺជាការខាតបង់ដល់សង្គមទាំងមូលតែម្តង។
  ២. កម្លាំងស្ត្រីចូលរួមនៅក្នុងកម្លាំងពលកម្មមានចំនួនជាង ៧០% នៃកម្លាំងពលកម្មសរុប ដូច្នេះ

ប្រសិនយើងព្រងើយកន្តើយ រើសអើងមនុស្សស្ត្រី ឬមានផ្នត់គំនិតយេនឌ័រ (Gender Stereotype) មានន័យថា យើងបានកាត់ចេញនូវកម្លាំងពលកម្មជាងពាក់កណ្តាល សម្រាប់ការអភិវឌ្ឍន៍ប្រទេស និងធ្វើឲ្យគ្មានសមភាពយេនឌ័រ

- **សារៈសំខាន់ នៃការប្រើប្រាស់ បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី: ការប្រឈម និងដំណោះស្រាយ៖**
  ១. ក្រសួង និងស្ថាប័នធ្វើការអំពីស្ត្រីសុទ្ធសឹងបានប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការកាត់បន្ថយអំពើហិង្សាលើស្ត្រី ដូចជាការផ្សព្វផ្សាយតាមអ៊ីនធឺណិត ការផ្តល់លេខទូរស័ព្ទរបស់ប៉ូលិសដល់អ្នកភូមិសម្រាប់ប្តឹងពេលមានអំពើហិង្សាកើតឡើង ការផ្សព្វផ្សាយតាមវិទ្យុ ការផ្សព្វផ្សាយតាមទូរទស្សន៍ ការបោះពុម្ព និងចែកខិតប័ណ្ណផ្សេងៗ។ល។
  ២. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាបានបង្កនូវភាពងាយស្រួលក្នុងការស្វែងរកឯកសារផ្សេងៗជាច្រើន ដែលមានសារៈសំខាន់ក្នុងការសរសេរគម្រោងផែនការ ឬសម្រាប់ការងារផ្សេងៗ។
  ៣. ការផ្សព្វផ្សាយព័ត៌មាន បានធ្វើមានការតាមឃ្លាំមើលពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិធ្វើអោយមានការកែប្រែ ឬបង្កើតបាននូវវិធានការ ឬយន្តការផ្សេងៗ ដើម្បីទប់ស្កាត់ នូវអំពើហិង្សាលើស្ត្រី និងកុមារ ឈានទៅរកការកាត់បន្ថយនូវសកម្មភាពមិនប្រក្រតី ឬការរំលោភបំពានផ្សេងៗ។
  ៤. គេអាចប្រើប្រាស់បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការផ្តល់អំណាចដល់ស្ត្រីសម្រាប់ការចងបណ្តាញពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ពីសហគមន៍មួយទៅសហគមន៍មួយ ដើម្បីកាត់បន្ថយផ្នត់គំនិតយេនឌ័រ ( Gender stereotype)
  ៥. បច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យាមានការរីកចម្រើន តែស្ត្រីនៅតំបន់អាស៊ីអាគ្នេយ៍មានចំនួនតិចដែរអាចប្រើប្រាស់វាបាន ដែលធ្វើឲ្យស្ត្រីឃ្លាតឆ្ងាយពីកន្លែងប្រមូលផ្តុំចំណេះដឹងពិភពលោក (pool of global knowledge) ដែលធ្វើឲ្យពួកគាត់បាត់បង់នូវឱកាសនៃការអភិវឌ្ឍន៍ខ្លួនឯង និងការអភិវឌ្ឍន៍សង្គម ។
  ៦. ក្នុងចំណោមអង្គការស្ត្រីចំនួន២៨ មានតែ៨អង្គការទេដែលមានវិបសាយ ក្នុងនោះ៦ជាវិបសាយភាសាអង់គ្លេស និង ២វិបសាយជាភាសាខ្មែរ ដែលមានព័ត៌មានភាគច្រើនជាប្រវត្តិរបស់អង្គភាព។ ចំពោះអង្គការដែលធ្វើការងារទាក់ទងនឹងសិទ្ធិមនុស្ស ចំនួន២៩ អង្គការមានតែ៩អង្គការទេដែលមានវិបសាយ និងភាគច្រើនជាភាសាអង់គ្លេស។

- **កិច្ចសហការរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី៖**
  ១. កន្លងមករដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបានធ្វើកិច្ចសហការគ្នាជាច្រើន ដូចជាក្នុងការបង្កើតឲ្យមានច្បាប់ប្រឆាំងអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការចូលរួមនៅក្នុងការដោះស្រាយបញ្ហាទាក់ទងនឹងអំពើហិង្សានៅតាមមូលដ្ឋាន
  ២. ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី បានធ្វើការងារផ្សព្វផ្សាយអនុសញ្ញាស៊ីដតាមបណ្តាខេត្តក្រុងជាច្រើន និងមានផ្តល់ជាវគ្គបណ្តុះបណ្តាល គ្រូបង្គោលអំពីអនុសញ្ញានេះផងដែរ
  ៣. អង្គការមិនមែនរដ្ឋាភិបាលមិនអាចធ្វើការជំនួសរដ្ឋាភិបាលទេ តែយើងអាចចូលរួមសហការ

និងធ្វើយ៉ាងណាដើម្បីឲ្យរដ្ឋាភិបាលបំពេញកាតព្វកិច្ចឲ្យបានប្រសើរថែមទៀត។

- **ចំណុចខ្វះខាត ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី៖**
  1. រហូតមកដល់ឥឡូវនេះ នៅមិនទាន់មានការស្រាវជ្រាវថ្នាក់ជាតិណាមួយបង្ហាញអំពីអំពើហិង្សាលើស្ត្រីនៅឡើយទេ(មានតែតាមស្ថាប័ន និងអង្គការផ្សេងៗដែលធ្វើដាច់ដោយឡែកពីគ្នា ព័ត៌មានជាន់គ្នា និងខ្វះលក្ខណៈប្រមូលផ្តុំ
  2. ករណីលែងលះនៅមូលដ្ឋានត្រូវបានប្រគល់ឲ្យក្រុមប្រឹក្សាឃុំ-សង្កាត់ និងថ្នាក់ស្រុកជាអ្នកអនុវត្ត តែមន្ត្រីតាមថ្នាក់ស្រុក និងមន្ទីរមិនសូវជាមានចំណេះដឹងផ្នែកផ្លូវច្បាប់ឡើយ
  3. ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីច្បាប់ និងអំពើហិង្សា យើងឃើញថាក្នុងចំណោមអង្គការដែលធ្វើការទាក់ទងស្ត្រី និងសិទ្ធិចំនួន២៨ មានតែ៨អង្គការទេដែលមានវិបសាយ ក្នុងនោះ៦ជាវិបសាយភាសាអង់គ្លេស និង ២វិបសាយជាភាសាខ្មែរ ដែលមានព័ត៌មានភាគច្រើនជាប្រវត្តិរបស់អង្គភាព។ ចំពោះអង្គការដែលធ្វើការងារទាក់ទងនឹងសិទ្ធិមនុស្ស ចំនួន២៩អង្គការមានតែ៩អង្គការទេដែលមានវិបសាយ និងភាគច្រើនជាភាសាអង់គ្លេស។
  4. គោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជាបានចែងថានៅឆ្នាំ២០១៥ យើងនឹងធ្វើឲ្យប្រជាពលរដ្ឋមានការយល់ដឹង១០០% ថា អំពើហិង្សាគឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ តែរហូតមកដល់ពេលនេះយើងមិនទាន់ឃើញមានការស្រាវជ្រាវណាមួយបង្ហាញអំពីតួលេខនៃការយល់ដឹងរបស់ប្រជាជនថាបានប៉ុន្មានភាគរយនោះនៅឡើយទេ។
  5. ការងារទប់ស្កាត់អំពើហិង្សាលើស្ត្រីត្រូវបានធ្វើស្ទើរតែគ្រប់ស្ថាប័ន ប៉ុន្តែគ្រាន់តែពុំទាន់បានដាក់បញ្ចូលលទ្ធផលទៅក្នុងរបាយការណ៍រួមថ្នាក់ជាតិ
  6. ចំណុចខ្សោយនៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យានោះគឺ ស្ត្រីដែលជាភេទទន់ខ្សោយ និងសហគមន៍ក្រីក្រ គឺមិនមានលទ្ធភាពក្នុងការប្រើប្រាស់ ដូច្នេះយើងគួរតែមានវិធីសំយោគរវាងការរីកចម្រើននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា និងសមាហរណកម្មនៃស្មារតីសង្គម ដើម្បីឲ្យយើងអាចប្រើប្រាស់បានគ្រប់គ្នា។
  7. ជាមួយគ្នានោះ ក្នុងការអនុវត្តការងារទាក់ទងអំពើហិង្សាលើស្ត្រី អង្គការមិនមែនរដ្ឋាភិបាលមួយចំនួនតែងជួបការលំបាកមួយចំនួនដូចជា៖ ជំនឿទូទៅរបស់ប្រជាពលរដ្ឋខ្មែរ អំពើពុករលួយ កង្វះភាពសហការពីអាជ្ញាធរ ប៉ូលិស និងតុលាការ និងភាពក្រីក្រ

## V. អនុសាសន៍

1. សំណូមពរឲ្យមានការស្រាវជ្រាវថ្នាក់ជាតិមួយបង្ហាញអំពីអំពើហិង្សាលើស្ត្រីនៅក្នុងប្រទេសកម្ពុជា
2. គួររដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល សហការគ្នាធ្វើការស្រាវជ្រាវរកសូចនាករនៃការយល់ដឹងរបស់ប្រជាពលរដ្ឋខ្មែរចំពោះអំពើហិង្សាលើស្ត្រី ដើម្បីឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍សហស្សវត្សកម្ពុជា ឆ្នាំ ២០១៥ ដែលបានចែងថា យើងនឹងធ្វើឲ្យប្រជាពលរដ្ឋមានការយល់ដឹង១០០% ថា អំពើហិង្សាគឺជាអាកប្បកិរិយាខុសឆ្គង និងជាបទឧក្រិដ្ឋ
3. រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរធ្វើការរួមគ្នានៅក្នុងខ្លឹមសារ និងដែនការងារ (frame-work) តែមួយ ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី

៤. គួរមានវិធីសំយោគរវាងការរីកចម្រើននៃបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា និង សមាហរណកម្មនៃស្មារតីសង្គម ដើម្បីឲ្យយើងអាចប្រើប្រាស់បានគ្រប់គ្នា
៥. រដ្ឋាភិបាល និងអង្គការ មិនមែនរដ្ឋាភិបាលគួរស្វែងរកយុទ្ធវិធីធ្វើការរួមគ្នាក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី ដោយគួរតែមានការចាប់អារម្មណ៍ទៅលើការផ្សព្វផ្សាយច្បាប់នានាទាក់ទងស្ត្រី និងអំពើហិង្សាលើស្ត្រី ដើម្បីឲ្យស្ត្រី ជាពិសេសស្ត្រីដែលនៅតាមទីជនបទមានការយល់ដឹងច្រើនជាងមុន
៦. រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលគួរបន្តធ្វើកិច្ចសហការគ្នាទៀត ដោយធ្វើការលើគម្រោងកម្មវិធីរួមមួយ តាមរយៈធ្វើកិច្ចសហការជាមួយក្រសួងកិច្ចការនារី និងអង្គការជាច្រើនដែលធ្វើការទាក់ទងនឹងការងារនេះ។

## VI. សេចក្តីសន្និដ្ឋាន

យោងតាមកិច្ចពិភាក្សា នៃកិច្ចប្រជុំវេទិកាស្ត្រី ដែលបានបង្ហាញនូវការរកឃើញ និងបានផ្តល់ជាអនុសាសន៍មួយចំនួននោះ យើងឃើញថា ទោះបីជារដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលមានកិច្ចសហការគ្នាយ៉ាងល្អក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី ក៏ដោយ ក៏កិច្ចការដែលយើងបានធ្វើកន្លងមក នៅមានចំណុចមួយចំនួនតម្រូវឲ្យមានការធ្វើឲ្យមានភាពប្រសើរឡើងថែមទៀត និងមានចំណុចមួយចំនួនដែលមិនទាន់បានធ្វើ និងទាមទារឲ្យមានការបំពេញ។

រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល គួរតែធ្វើការរួមគ្នាលើគម្រោងមួយ ដែលមានលក្ខណៈប្រមូលផ្តុំនូវកម្លាំងដ៏ខ្លាំង និងមានគោលដៅជារួមមួយក្នុងការទប់ស្កាត់ និងលុបបំបាត់អំពើហិង្សាលើស្ត្រី ដើម្បីជាការទាក់ទាញដល់ម្ចាស់ជំនួយ និងមានឥទ្ធិពលទៅលើយុទ្ធសាស្ត្រនៃការបែងចែកជំនួយរបស់អង្គការម្ចាស់ជំនួយ។

សម្រាប់របាយការណ៍លម្អិតនៃកិច្ចប្រជុំវេទិកាស្ត្រីដំណាក់កាលទី២ ទាំងបីលើក ស្តីពី «**តម្រូវការបច្ចេកវិទ្យា គមនាគមន៍ ព័ត៌មានវិទ្យា ក្នុងការបញ្ចប់អំពើហិង្សាលើស្ត្រី**» សូមចូលអាន **http://women.open.org.kh/km/womenfourm-reclaiming-ict-end-vaw-report** ។

**ភ្នំពេញ ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០០៨**

**រៀបចំដោយ៖ អង្គការវិទ្យាស្ថានបើកទូលាយ**